**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលការអនុវត្តន៍បើកប្រាក់សោធនចំពោះមន្ត្រីរាជការ ដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ

**********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៧ / នស / ៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស / រកម / ១១៩៧ / ០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៤០៦ / ០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញក្រឹត្យលេខ ១០ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ១២០១ / ៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០១០៨ / ០៣៩ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តនីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលការអនុវត្តនីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សរ៍ថ្មី
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តនីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្តីពីរបបឧបត្ថម្ភយោធិនពលីមរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយ ចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់ការកែសម្រួលការអនុវត្តន៍បើកប្រាក់សោធន ចំពោះមន្ត្រីរាជការដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ និងអ្នកនៅក្នុងបន្ទុក។

**មាត្រា ២ .-**

និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ ដែលទទួលមុខតំណែងជាអ្នកនយោបាយ ត្រូវបានអនុញ្ញាតឱ្យបើកប្រាក់សោធនប្រចាំខែឡើងវិញ។ ចំពោះប្រាក់សោធនប្រចាំខែ ដែលត្រូវបានផ្អាកក្នុងរយៈពេលទទួលមុខតំណែងជាអ្នកនយោបាយ មិនត្រូវបានគិតប្រាក់រំលឹកជូនសាមីជនវិញឡើយ។

ចំពោះគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ និងអ្នកនៅក្នុងបន្ទុក ត្រូវបានអនុញ្ញាតឱ្យបើកប្រាក់ឧបត្ថម្ភប្រចាំខែផងដែរ ស្របតាមគោលការណ៍ដែលបានកំណត់។

**មាត្រា ៣ .-**

មន្ត្រីដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ ក្នុងពេលបំពេញមុខដំណែង ហើយទទួលបានប្រាក់បំណាច់តាមមុខដំណែង និងប្រាក់សោធនប្រចាំខែឡើងវិញហើយនោះ មិនត្រូវបានអនុញ្ញាតឱ្យមានឈ្មោះជាមន្ត្រីជាប់កិច្ចសន្យា និងទទួលបានប្រាក់កំរៃជាមន្ត្រីជាប់កិច្ចសន្យាបន្ថែមទៀតឡើយ ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ